**គម្រោងបង្ហាញបច្ចេកវិទ្យាបង្កើនផលិតភាព**
**ជុំវិញតំបន់ទន្លេសាប** ( TSTD TA 7305-CAM )

# បច្ចេកទេសដាំដំណាំត្រសក់ផ្អែម



## ក. សេចក្តីផ្តើម

ខិត្តប័ណ្ណ បច្ចេកទេសដាំដំណាំត្រសក់ផ្អែម នេះ ត្រូវបានរៀបចំឡើងសម្រាប់កសិករ ដោយផ្អែកលើបទពិសោធន៍ធ្វើបង្ហាញបច្ចេកទេសដាំដំណាំនេះ ក្នុងរដូវប្រាំង ដើមឆ្នាំ ២០១២ នៅ ខេត្តកំពង់ចាម និង កំពង់ធំ។ ខ្លឹមសារលំអិត រៀបរាប់ក្នុងខិត្តប័ណ្ណនេះ មានក្នុង *សៀវភៅណែនាំបច្ចេកទេសកសិករ ស្តីពីដំណាំត្រសក់ផ្អែម* ដែលអាចរកបាន តាមមន្ទីរកសិកម្មខេត្តគោលដៅ និងមណ្ឌលព័ត៌មានកសិករជនបទ ហើយអាចរកបានជាទម្រង់អេឡិចត្រូនិច តាមអាសយដ្ឋានវេបសាយ www.telecentercambodia.org។ ខ្លឹមសារស្តីពីសត្វល្អិត និងជម្ងឺ និង ការគ្រប់គ្រងការពារ សម្រាប់ដំណាំត្រសក់ផ្អែមនេះ មិនមានបញ្ចូលក្នុងខិត្តបណ្ណ័ នេះឡើយ។

| រូបភាព | ពិពណ៌នា | អាយុត្រសក់ |
|---|---|---|
| ១ | ▪ រៀបចំរង (លើកពូនរង ដាក់ជីទ្រាប់បាត រៀបប្រព័ន្ធស្រោចស្រពតំណក់ទឹក និង ក្រាលកៅស៊ូគ្របរង) | ថ្ងៃទី ១ |
| ២ | ▪ បណ្តុះកូន | ថ្ងៃទី ២ |
| ៣ | ▪ ថែទាំកូន ក្នុងរោងកូនធ្វើសំណាញ់មុងពណ៌ស (ដាំនៅពេលកូនមានអាយុ ១២ថ្ងៃ) | ថ្ងៃទី ១២ទៅទី ១៤ |
| ៤ | ▪ **ការដាំកូន** (ចោះកៅស៊ូគម្របរងដោយកំប៉ុងក្តៅ ភ្លាមមុនពេលដាំ (ហាមចោះទុកយូរ ក្រដាំ) | ថ្ងៃទី ១៤ |
| ៥ | ▪ រៀបចំទ្រើង ខ្សែចងដើម និង ការថែទាំ<br>▪ គាក់តែងមែកផ្កា កាត់ខ្នែង និងផ្កាក្តិបដែលមិនត្រូវការ និងការរុំដើមឱ្យតោងខ្សែទ្រើង ។ (ចាប់ពី១២ថ្ងៃ បន្ទាប់ពីដាំ ហើយបន្តកាត់ត្រួយខ្នែង/ផ្កា រហូតដល់ពេលប្រមូលផល)<br>▪ ប្រើប្រាស់ជីកំប៉ុស្តិ៍ទឹកជំនួយដើមស្លឹក ចាប់ពីក្រោយដាំបាន ៧ ថ្ងៃ (៥ ថ្ងៃម្តង) ដើម្បីឱ្យដើមលូតលាស់បានល្អ រហូតដល់ទុកបានក្តិប ទើបប្តូរទៅប្រើប្រាស់ ជីទឹកជំនួយផ្លែវិញ | ថ្ងៃទី ១៤<br>ដល់ ថ្ងៃទី ៧៥ |
| ៦ | ▪ រើសបំរុងក្តិបកាន់ផ្លែ (ចំនួន ៣ នៅថ្នាំងពីទី ៨ ដល់ ១៣)<br>▪ កាត់ត្រួយខ្នែងដែលទុកក្តិប និងតាមដានសត្វល្អិតចង្រៃ ជម្ងឺ និង ការវិវឌ្ឍន៍របស់ដំណាំ | ថ្ងៃទី ៤៥<br>(៣០ថ្ងៃបន្ទាប់ពីដាំ) |
| ៧ | ▪ ជ្រើសរើសយកក្តិប ១ ទុកឱ្យធំយកផ្លែ (ចន្លោះពី ៣០ ទៅ ៤៥ ថ្ងៃ បន្ទាប់ពីដាំកូន)<br>▪ ចងយួរបន្តោងផ្លែ ឱ្យផុតពីដី (※ មិនត្រូវទាញខ្នែងមានក្តិបខ្លាំងពេក ប្រយ័ត្នកាច់គ្រេចខ្នែងផ្លែ) | ថ្ងៃទី ៤៥<br>ដល់ថ្ងៃទី ៦០ |
| ៨ | ▪ ក្រៀវត្រួយដើមមេ បន្ទាប់ពីចេញផុតស្លឹកទី ២៣ ដល់ ២៥ ។ | ថ្ងៃទី ៦០ |
| ៩ | ▪ ថែទាំដើម ផ្លែ និង ស្រោចទឹក។<br>▪ ស្រោចទឹក រៀងរាល់ ២ថ្ងៃម្តង និងជីកំប៉ុស្តិ៍ទឹកជំនួយផ្លែផ្អែម រៀងរាល់ ៥-៧ ថ្ងៃម្តង។ | ថ្ងៃទី៤៥<br>ដល់ថ្ងៃទី៧៥ |
| ១០ | ▪ ដំណាក់កាលទុំ ។ ជាទូទៅវាអាចចាប់ផ្តើមទុំចាប់ពីអាយុកាល ៦០ ថ្ងៃ បន្ទាប់ពីដាំកូន អាស្រ័យលើលក្ខខណ្ឌអាកាសធាតុ (រដូវប្រាំង ក្តៅ ឆាប់ទុំ)។ | ថ្ងៃទី ៧០<br>ដល់ថ្ងៃទី៨០ |
| ១១ | ▪ ប្រមូលផល ។ ការថែទាំ ដើមឱ្យនៅរស់រហូតដល់ដំណាក់កាលប្រមូលផល។<br>▪ ប្រមូលផលបណ្តើៗ តែផ្លែទុំល្អ និង រើសផ្លែធំស្មើ វេចខ្ចប់ដាក់កេះ/ឡាំង សម្រាប់លក់ | ថ្ងៃទី ៧០ - ៨០<br>(អាស្រ័យតាមពូជ) |

## ខ. តម្រូវការទូទៅ និង រដូវកាលដាំដុះ

ត្រសក់ផ្អែម ត្រូវការពន្លឺថ្ងៃ ហើយងាយនឹងរងការបំផ្លាញពីជម្ងឺ និងសត្វល្អិត។ ត្រសក់នេះងាយរងជម្ងឺផ្សិត និងសត្វល្អិតបំផ្លាញជាងដំណាំក្នុងអំបូរវា (ដូចជា ត្រសក់ ឪឡឹក ត្រឡាច) ដូច្នេះ មិនត្រូវដាំវាជាប់ក្បែរ ក្រោមខ្យល់ដំណាំទាំងនេះ ឬ ដំណាំស្ពៃខាត់ណាឡើយ។ ជាទូទៅត្រសក់ផ្អែម តែងជួបប្រទះ ជម្ងឺ និងការបំផ្លាញពីសត្វល្អិត ប៉ុន្តែការបំផ្លាញ អាចជះផលប៉ះពាល់អាក្រក់ខ្លាំងដល់ផលត្រសក់ សារតែដំណាំនេះ ទុកតែមួយផ្លែ។ បើជម្ងឺ ឬ សត្វល្អិតធ្វើឱ្យខូចខាតដល់មួយដើម គឺ បាត់ផល ១ដើម តែម្តង។ ដូច្នេះ វិធានការបង្ការការពារ (ការរើសទីតាំងចំការ ការថែទាំកូន និង ការសំអាត អនាម័យចំការ) អាចរួមចំណែកកាត់បន្ថយការខូចខាត។ ការថែទាំ និងពិនិត្យតាមដានដំណាំ ជាប្រចាំ គឺជាការចាំបាច់។

រដូវដាំដុះដែលល្អបំផុត សម្រាប់ដំណាំនេះ នៅកម្ពុជា គឺ រដូវប្រាំង បន្ទាប់ពីភ្លៀងចាប់ដើមអស់ និងទឹកស្រកចុះ ទៅតាមទីតាំងចំការ (ដីទួល ឬ ដីស្រែ)។ ពេលសមស្របខ្លាំង សម្រាប់ចាប់ផ្តើមដាំ គឺពីខែធ្នូ ដល់ ខែកុម្ភៈ។ ដីស្រែមានល្បាយខ្សាច់ ផ្តល់ផ្លែតូច តែស្រួយ និង ផ្អែមជាង ដីល្បាប់កណ្តោង។ ដើម្បីដាំដំណាំនេះឱ្យបានផល និង គុណភាពល្អ កសិករត្រូវការជីកំប៉ុស្តិ៍ ៣ ប្រភេទ គឺ កំប៉ុស្តិ៍គោក កំប៉ុស្តិ៍ទឹកបំប៉នស្លឹកដើម និង កំប៉ុស្តិ៍ទឹកជំនួយផ្លែឱ្យផ្អែម។ របៀបធ្វើ និង ប្រើជីទាំងនេះ មាននៅក្នុងខិត្តប័ណ្ណធ្វើជីកំប៉ុស្តិ៍ និង សៀវភៅណែនាំបច្ចេកទេស ស្តីពីដំណាំនេះ។

## គ.វិធីដាំ និង ថែទាំ

### *គ.១. ការបណ្តុះកូនត្រសក់*

ថ្នាលបណ្តុះកូន ត្រូវដាក់នៅកន្លែង ដែលមានកំដៅថ្ងៃល្អ។ គេអាចប្រើដីបណ្តុះកូនលាយស្រាប់ ដែលអាចទិញបានពីផ្សារ ឬ រៀបចំដីបណ្តុះកូន ដែលផ្សំ (ក្នុងបរិមាណស្មើគ្នា) ពី៖ ស្រកីដូងម៉ដ្ឋ ដីស្រទាប់លើ ដីកំប៉ុស្តិ៍គោក និង ផេះធ្យូងអង្កាម ហើយចំហិនសំលាប់មេរោគបានល្អ។ ខាងក្រោម ជាវិធីបណ្តុះកូនត្រសក់៖



- ដាស់ដំណេកគ្រាប់សិន ដោយដាក់គ្រាប់ត្រាំក្នុងទឹកក្តៅអ៊ុនៗ
- យកដីខ្សាច់ លាងឱ្យស្អាត រួចដាក់ហាលថ្ងៃ ឬ លីងដីខ្សាច់ឱ្យបានស្ងួតល្អ រួចទុកមួយឡែក។
- ចាក់ទឹកក្តៅ១កូនកែវ សម្រាប់ដីខ្សាច់ ១គីឡូ(ផ្សើមដីតិចៗ)។



- ដាក់ក្រណាត់ដែលមានពង្រាយគ្រាប់ត្រសក់ នៅលើដីខ្សាច់នោះ រួចខ្ចប់រុំក្រណាត់ឱ្យជិតល្អ ហើយដាក់ដីខ្សាច់គ្របពីលើ ផ្អាប់ក្នុងធុងទឹកកក ដែលដាក់ហាលថ្ងៃរយៈពេល ២៤ ម៉ោង ទើបយកគ្រាប់ចេញពន្លក ទៅដាក់លើថាសបណ្តុះកូន។